# ព័ត៌មានលម្អិត និងសកម្មភាពការស្រមៃ មើលលូកា ១៧

សៀវភៅសិក្សាព្រះគម្ពីរសញ្ញាថ្មីសម្រាប់ថ្នាក់សិក្ខាសាលា

**សូមអាន លូកា ១៧:១១–១៤ ដោយយកចិត្តទុកដាក់ ដោយផ្ដោតលើព័ត៌មានលម្អិត ។**

បន្ទាប់ពីបានអានហើយ សូមព្យាយាមឆ្លើយសំណួរទាំងប្រាំខាងក្រោមនេះឲ្យបានច្រើនតាមដែលអាចធ្វើទៅបាន ដោយមិនចាំបាច់យោងទៅលើបទគម្ពីរនោះទេ ។

១. តើមនុស្សឃ្លង់ទាំងនោះបានចូលទៅជិតព្រះអង្គសង្គ្រោះប៉ុណ្ណាដែរ ?

២. តើមនុស្សឃ្លង់ទាំងនោះបានទូលសូមអ្វីខ្លះពីព្រះអង្គសង្គ្រោះ ?

៣. តើព្រះអង្គសង្គ្រោះបានមានបន្ទូលអ្វីខ្លះទៅកាន់ពួកគេ ?

៤. តើមានមនុស្សឃ្លង់ប៉ុន្មាននាក់ដែលមានសេចក្ដីជំនឿ ដើម្បីធ្វើអ្វីដែលព្រះអង្គសង្គ្រោះបានបង្គាប់ ?

៥. តើមនុស្សឃ្លង់ទាំងនោះបានធ្វើអ្វីខ្លះ នៅពេលដែលពួកគេបានជាសះស្បើយ ?

**សូមស្រមៃអំពីអ្វីដែលអ្នកអាន ។**

សូមស្រមៃថា ខ្លួនអ្នកជាមនុស្សឃ្លង់ម្នាក់ដែលត្រូវបានសម្អាត ។

- តើការដែលបានប្រោសឲ្យជាពីជំងឺឃ្លង់អាចមានលក្ខណៈដូចម្ដេចទៅ ? តើអ្នកនឹងមានអារម្មណ៍ដូចម្ដេច ?
- ហេតុអ្វីអ្នកគិតថា ការជាសះស្បើយនៅក្នុងដំណើររឿងនេះកើតឡើង « លុះគេកំពុងតែដើរទៅ » ? ( ខទី ១៤ ) ។
- តើអ្នកគិតថា អ្នកនឹងធ្វើអ្វីខ្លះ នៅពេលអ្នកបានដឹងថា ព្រះអង្គសង្គ្រោះបានព្យាបាលអ្នកឲ្យជានោះ ?

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

© ២០២២ by Intellectual Reserve, Inc. All rights reserved. កំណែ ៖ ២/២១ ។ ការបកប្រែនៃ *Luke 17 Details and Visualizing Activity.*
Cambodian. PD60012661 258. Printed in the United States of America.